# ព័ត៌មានសង្ខេបស្តីអំពី
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)

មិថុនា ២០១១

## កាលប្បវត្តិនៃការបង្កើត អ.វ.ត.ក

**១៧ មេសា ១៩៧៥** — ខ្មែរក្រហមដែលដឹកនាំដោយ ប៉ុល ពត បានកាន់កាប់អំណាចនៅកម្ពុជា។ ប្រជាជនកម្ពុជាជាង១,៧លាននាក់បានស្លាប់មុនពេលដែលរបបនេះត្រូវបានផ្តួលរំលំនៅថ្ងៃ៧ មករា ១៩៧៩។

**១៥ សីហា ១៩៧៩** — តុលាការប្រជាជនបដិវត្តន៍កម្ពុជាបានជំនុំជម្រះ អៀង សារី និង ប៉ុល ពត ពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។ តុលាការនេះពុំមានការទទួលស្គាល់ពីសហគមន៍អន្តរជាតិទេ ព្រោះវាពុំមានបទដ្ឋានយុត្តិធម៌អន្តរជាតិ។

**២១ មិថុនា ១៩៩៧** — រាជរដ្ឋាភិបាលកម្ពុជាស្នើទៅ អ.ស.ប សុំជំនួយអន្តរជាតិដើម្បីបង្កើតតុលាការមួយកាត់សេចក្តីអតីតមេដឹកនាំខ្មែរក្រហម។

**១៥ មីនា ១៩៩៩** — អ្នកជំនាញ អ.ស.ប លើកសំណើអំពីតុលាការសិទ្ធិមនុស្សមួយនៅក្រៅប្រទេសកម្ពុជា ដោយយកគំរូតាមតុលាការឧក្រិដ្ឋកម្មសម្រាប់ប្រទេសដទៃ។ រាជរដ្ឋាភិបាលកម្ពុជាបដិសេធសំណើនេះ ហើយការចរចាបានអូសបន្លាយពេលវេលាយ៉ាងវែង។

**១០ សីហា ២០០១** — ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តី ឧក្រិដ្ឋកម្មកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានប្រកាស ក៏ប៉ុន្តែ អ.ស.ប និងរាជរដ្ឋាភិបាលកម្ពុជាពុំទាន់ឈានដល់កិច្ចព្រមព្រៀងនៅឡើយទេ។

**៨ កុម្ភៈ ២០០២** — អ.ស.ប បានប្រកាសដកខ្លួនចេញពីការចរចាជាមួយរាជរដ្ឋាភិបាលកម្ពុជា អំពីតុលាការខ្មែរក្រហម។

**៦ មិថុនា ២០០៣** — នៅរាជធានីភ្នំពេញ រាជរដ្ឋាភិបាលកម្ពុជានិង អ.ស.ប បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីការជំនុំជម្រះក្តីនៅក្រោមច្បាប់កម្ពុជាចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងក្រោមរបបកម្ពុជាប្រជាធិបតេយ្យ។

**២៧ តុលា ២០០៤** — សេចក្តីប្រកាសអំពីវិសោធនកម្មលើច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**១៨ មករា ២០០៦** — រាជរដ្ឋាភិបាលកម្ពុជាប្រគល់ឲ្យ អ.វ.ត.ក នូវទីតាំងមួយកន្លែងដែលស្ថិតនៅជាប់នឹងអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ។

**៨ កុម្ភៈ ២០០៦** — បុគ្គលិកបានចូលធ្វើការជាលើកដំបូងបំផុត

**៣ កក្កដា ២០០៦** — ចៅក្រមជាតិនិងអន្តរជាតិធ្វើពិធីស្បថចូលកាន់តំណែង

**១២ មិថុនា ២០០៧** — អ.វ.ត.ក អនុម័តវិធានផ្ទៃក្នុង ដើម្បីឲ្យតុលាការដំណើរការបានយ៉ាងពេញលេញ

## អ.វ.ត.ក ជាតុលាការកូនកាត់

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានបង្កើតឡើងដើម្បីកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ (របបខ្មែរក្រហម) ចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។ នៅក្នុងអំឡុងពេលនោះ ប្រជាជនប្រមាណ ១,៧លាននាក់ ត្រូវបានជឿជាក់ថាស្លាប់ដោយកង្វះអាហារ ទារុណកម្ម ការកាប់សម្លាប់ និងការបង្ខំឲ្យធ្វើការបាក់កម្លាំង។ អង្គជំនុំជម្រះនេះ ដែលស្គាល់ជាទូទៅថា តុលាការខ្មែរក្រហម ត្រូវបានរំពឹងថានឹងជួយបិទទំព័រខ្មៅងងឹតនៃប្រវត្តិសាស្ត្រកម្ពុជា។

អ.វ.ត.ក គឺជាតុលាការកម្ពុជាដែលមានការចូលរួមពីអន្តរជាតិ ត្រូវបានបង្កើតឡើងក្រោមច្បាប់កម្ពុជា។ កិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិឆ្នាំ២០០៣ ផ្តល់លក្ខខណ្ឌឲ្យមានជំនួយបច្ចេកទេសនិងការចូលរួមរបស់អន្តរជាតិ។

## ដែនយុត្តាធិការ

អ.វ.ត.ក ត្រូវបានបង្កើតឡើងក្នុងគោលបំណងផ្តល់ការជំនុំជម្រះក្តីដោយយុត្តិធម៌និងស្របតាមនិយាមអន្តរជាតិ។ អ.វ.ត.ក មានគោលដៅស្វែងរកយុត្តិធម៌ជូនប្រជាជនកម្ពុជា ទាំងអ្នកដែលបានបាត់បង់ជីវិត និងអ្នកដែលនៅរស់រានមានជីវិត ពីមហាវិនាសកម្មកាលពីជាងបីទសវត្សរ៍មុន។

ដែនយុត្តាធិការលើពេលវេលា ៖

- អំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ចន្លោះថ្ងៃ ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ៦ មករា ១៩៧៩

ដែនយុត្តាធិការលើបុគ្គល ៖

- មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ
- អ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

ដែនយុត្តាធិការតាមសាច់រឿង ៖

- ទារុណកម្ម មនុស្សឃាត និងការរើសអើងដោយមូលហេតុសាសនា ក្រោមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦
- អំពើប្រល័យពូជសាសន៍
- ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ
- ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩
- ការបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌ក្នុងអំឡុងពេលសង្គ្រាម
- ឧក្រិដ្ឋកម្មប្រឆាំងនឹងជនដែលត្រូវបានការពារដោយអនុសញ្ញាទីក្រុងវីយែនឆ្នាំ១៩៦១ស្តីអំពីទំនាក់ទំនងការបរទេស

# រចនាសម្ព័ន្ធនៃ អ.វ.ត.ក




## បុគ្គលិក

អ.វ.ត.ក មានទាំងបុគ្គលិកនិងអ្នកច្បាប់ជាតិនិងអន្តរជាតិ។

គម្រោងថវិកាថ្មីរបស់ អ.វ.ត.ក សម្រាប់ឆ្នាំ២០១១ អនុញ្ញាតឲ្យ អ.វ.ត.ក ជួលបុគ្គលិកចំនួន ៤៧៩នាក់។ ២ភាគ៣នៃបុគ្គលិកទាំងអស់គឺជាបុគ្គលិកជាតិក្រោមកិច្ចសន្យាជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្រៅពីនេះគឺជាបុគ្គលិករបស់ អ.ស.ប។

## ហិរញ្ញវត្ថុ

ថវិកាដែលចំណាយសម្រាប់ដំណើរការរបស់ អ.វ.ត.ក គឺបានមកពីជំនួយវិភាគទានស្ម័គ្រចិត្តរបស់បណ្តាប្រទេសម្ចាស់ជំនួយ។ រាជរដ្ឋាភិបាលកម្ពុជានិង អ.ស.ប ទទួលខុសត្រូវក្នុងការចាត់ចែងខ្ទង់ចំណាយ៖

| | ភាគីជាតិ | ភាគីអន្តរជាតិ | សរុប |
|---|---|---|---|
| ចំណាយ ២០០៦-២០១០ | $២៤,១ លាន | $៨៥.០ លាន | $១០៩,២ លាន |
| គម្រោងថវិកា ២០១១ | $៩,៩ លាន | $៣០,៨ លាន | $៤០,៧ លាន |

**ម្ចាស់ជំនួយធំៗ** ៖ ជប៉ុន អូស្ត្រាលី បារាំង អាល្លឺម៉ង់ ចក្រភពអង់គ្លេស សហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប

# នីតិវិធីនៅ អ.វ.ត.ក

យោងតាមច្បាប់តុលាការខ្មែរក្រហម កិច្ចព្រមព្រៀង និងវិធានផ្ទៃក្នុង ការកាត់សេចក្ដីនៅចំពោះមុខ អ.វ.ត.ក ប្រព្រឹត្តទៅនៅក្នុងក្របខ័ណ្ឌប្រព័ន្ធច្បាប់ស៊ីវិល និងតាមដំណាក់កាលដូចខាងក្រោម ៖

## ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

នេះគឺជាឯកសារលាយលក្ខណ៍អក្សរដែលសហព្រះរាជអាជ្ញាស្នើសុំទៅសហចៅក្រមស៊ើបអង្កេតឲ្យបើកការស៊ើបអង្កេត និងលើកសំណើសុំចោទប្រកាន់។

## ការស៊ើបអង្កេតតាមផ្លូវតុលាការ

សហចៅក្រមស៊ើបអង្កេតចាប់ផ្ដើមស៊ើបអង្កេតតែទៅលើអង្គហេតុដែលបានលើកឡើងនៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ (និងដីកាបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ប្រសិនបើមាន) ហើយប្រហែលជាចោទប្រកាន់បុគ្គលណាម្នាក់ដែលបានលើកឡើងនៅក្នុងដីកានោះ។

## សវនាការនៅចំពោះមុខអង្គបុរេជំនុំជម្រះ

ភាគីអាចប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត អាចស្នើសុំឲ្យធ្វើមោឃភាពកិច្ចស៊ើបសួរ ឬអាចស្នើឲ្យដាក់ទណ្ឌកម្មលើបុគ្គលណាដែលត្រូវបានចោទប្រកាន់ថាជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ។

## សេចក្ដីសន្និដ្ឋានស្ថាពរ

គឺជាឯកសារលាយលក្ខណ៍អក្សរដែលសហព្រះរាជអាជ្ញាស្នើសុំទៅសហចៅក្រមស៊ើបអង្កេតឲ្យចោទប្រកាន់ ឬតម្កល់សំណុំរឿងទុកមិនចាត់ការ។

## ដីកាដំណោះស្រាយ

ជាឯកសារដែលរៀបរៀងដោយសហចៅក្រមស៊ើបអង្កេតនៅចុងបញ្ចប់នៃការស៊ើបអង្កេតតាមផ្លូវតុលាការ។ វាគឺជាសេចក្ដីសម្រេចចិត្តថានឹងត្រូវចោទប្រកាន់ ឬលើកលែងការចោទប្រកាន់ និងក៏ជាសេចក្ដីសម្រេចចិត្តថាទទួលឬមិនទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។ ដីកាដំណោះស្រាយបើកផ្លូវឲ្យមានបណ្ដឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ។

## ការកាត់សេចក្ដី

សហព្រះរាជអាជ្ញា ដើមបណ្ដឹងរដ្ឋប្បវេណី មេធាវីការពារក្ដី និងជនជាប់ចោទ ដាក់ភ័ស្ដុតាងនិងសាក្សីជូនតុលាការ និងវិភាគភ័ស្ដុតាងនិងសាក្សីរបស់ភាគីដទៃ ដើម្បីធានាការពិត។

## សាលក្រម

អង្គជំនុំជម្រះសាលាដំបូងសម្រេចចិត្តទៅលើសំណុំរឿង។ ប្រសិនបើរកឃើញថាជនជាប់ចោទមានទោស អង្គជំនុំជម្រះសាលាដំបូងនឹងចេញសាលក្រមដាក់ទោស ហើយប្រសិនបើអាច ផ្ដល់សំណងរដ្ឋប្បវេណីដល់ជនរងគ្រោះ។

## ការប្ដឹងសាទុក្ខទៅអង្គជំនុំជម្រះតុលាការកំពូល

សហព្រះរាជអាជ្ញា មេធាវីការពារក្ដី និងដើមបណ្ដឹងរដ្ឋប្បវេណី អាចដាក់ពាក្យបណ្ដឹងសាទុក្ខប្រឆាំងនឹងសេចក្ដីសម្រេចចិត្តរបស់អង្គជំនុំជម្រះសាលាដំបូង។ សេចក្ដីសម្រេចចិត្តរបស់អង្គជំនុំជម្រះតុលាការកំពូលគឺជាសេចក្ដីសម្រេចចិត្តចុងក្រោយនិងបិទផ្លូវតវ៉ា។

# សំណុំរឿងនៅ អ.វ.ត.ក

បច្ចុប្បន្ននេះ អ.វ.ត.ក កំពុងដោះស្រាយសំណុំរឿងចំនួន ៤ និងកំពុងឃុំខ្លួនអ្នកទោសមួយរូប និងជនជាប់ចោទបួនរូប នៅក្នុងសំណុំរឿង ០០១ និង ០០២។

## សំណុំរឿង ០០១



*កាំង ហ្គេកអ៊ាវ ហៅ ឌុច*

មានជនជាប់ចោទ១រូបគឺ កាំង ហ្គេកអ៊ាវ ហៅ ឌុច អតីតប្រធានមន្ទីរសន្តិសុខ ស-២១ (ទួលស្លែង) នៅទីក្រុងភ្នំពេញ។ គាត់ត្រូវបានជំនុំជម្រះពីបទ**ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ** និង**ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩** និងត្រូវផ្តន្ទាទោសកាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឲ្យជាប់ពន្ធនាគាររយៈពេល៣៥ឆ្នាំ។ ទាំងសហព្រះរាជអាជ្ញា និងមេធាវីការពារក្តី ព្រមទាំងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន បានប្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចចិត្តនេះ។ សវនាការលើបណ្តឹងសាទុក្ខបានប្រព្រឹត្តទៅកាលពីថ្ងៃ ២៨-៣០ ខែមីនា ឆ្នាំ២០១១។

## សំណុំរឿង ០០២






*ពីឆ្វេងទៅស្តាំ: នួន ជា (អតីតអនុលេខាបក្សកុម្មុយនីស្តកម្ពុជា) ខៀវ សំផន (អតីតប្រមុខរដ្ឋ) អៀង សារី (អតីតឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការការបរទេស) និង អៀង ធីរិទ្ធ (អតីតរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច)*

មានជនជាប់ចោទ៤រូបគឺ **នួន ជា**, **ខៀវ សំផន**, **អៀង សារី** និង **អៀង ធីរិទ្ធ** ត្រូវបានជឿជាក់ថាជាមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលនៅរស់រានមានជីវិត។ អ្នកទាំង៤ត្រូវបានចោទប្រកាន់អំពីបទល្មើស **ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ** (ការសម្លាប់ផ្តាច់ពូជ ការដាក់ជាទាសករ ការនិរទេសការឃុំឃាំង ការធ្វើទារុណកម្ម ការរើសអើង) **ការរំលោភ បំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩** (មនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ការឃុំឃាំងជនស៊ីវិលដោយខុសច្បាប់ និងអំពើអមនុស្សធម៌ផ្សេងៗទៀត) **អំពើប្រល័យពូជសាសន៍** (ការសម្លាប់រង្គាលជនជាតិភាគតិចចាមនិងវៀតណាម) **បទល្មើសក្រោមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦** (មនុស្សឃាត ការធ្វើទារុណកម្ម ការរើសអើងដោយហេតុផលសាសនា)។ សវនាការបឋមលើរឿងក្តីនេះនឹងចាប់ផ្តើមនៅថ្ងៃ ២៧-៣០ ខែមិថុនា ឆ្នាំ២០១១។

## សំណុំរឿង ០០៣ និង ០០៤

សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ដីកាបញ្ជូនសំណុំរឿងឲ្យស៊ើបសួរ ទៅឲ្យសហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី ៧ ខែកញ្ញា ឆ្នាំ២០០៩ ស្នើសុំឲ្យមានការស៊ើបអង្កេតលើជនសង្ស័យចំនួន៥រូបបន្ថែមទៀត។ កាលពីថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេតបានប្រកាសអំពីការចេញដីកាសន្និដ្ឋានការស៊ើបអង្កេតលើសំណុំរឿង ០០៣។ សម្រាប់សំណុំរឿង ០០៤ សហចៅក្រមស៊ើបអង្កេតកំពុងតែបន្តការស៊ើបអង្កេតតាមផ្លូវតុលាការ។

## ការគាំទ្រនិងការចូលរួមរបស់សាធារណជន

ដោយសារមានទីតាំងនៅក្នុងប្រទេសកម្ពុជា ជាទីកន្លែងដែលអំពើឧក្រិដ្ឋកម្មបានកើតឡើង អ.វ.ត.ក បានទទួលការចូលរួមពីសាធារណជនក្នុងចំនួនដ៏ច្រើនលើសលុប។

- សាធារណជនជាង ៣១.៣០០នាក់ រួមទាំងតំណាងសារព័ត៌មានចំនួន ៣.៦៤០នាក់ បានតាមដានសវនាការសំណុំរឿង ០០១ ក្នុងឆ្នាំ២០០៩
- ប្រជាជនសរុបចំនួន ៣៤.៥០០នាក់ បានធ្វើទស្សនកិច្ចនៅតុលាការក្នុងឆ្នាំ២០១០ តាមរយៈកម្មវិធីផ្សព្វផ្សាយ រួមមាន៖

  - ដំណើរទស្សនកិច្ចសិក្សានៅសាលាក្ដីខ្មែរក្រហម ចំនួន៨០ដង អ្នកចូលរួមចំនួន ២៩.២៩១នាក់ មកពី២៤ខេត្តក្រុង
  - សវនាការសាធារណៈ សាធារណជនចំនួន ២.៣៧៦នាក់ បានចូលរួមតាមដានសវនាការនៃអង្គបុរេជំនុំជម្រះចំនួន៤ ហើយ ៩៥០នាក់ទៀតបានចូលរួមស្ដាប់សវនាការប្រកាសសាលក្រមសំណុំរឿង ០០១
  - ការធ្វើទស្សនកិច្ចជាក្រុមមានចំនួន៦៩ក្រុម សរុប ១៧៨០នាក់
  - ទស្សនកិច្ចរបស់មន្ត្រីជាន់ខ្ពស់ មានគណៈប្រតិភូចំនួន២៣ សរុបប្រតិភូ ១៥១នាក់
- ជារៀងរាល់ឆ្នាំ មានសិស្សនិងនិស្សិតរាប់ពាន់នាក់បានទទួលបទឧទ្ទេសនាមស្ដីអំពីយុត្តាធិការនិងការវិវឌ្ឍរបស់ អ.វ.ត.ក

## ការយល់ឃើញរបស់សាធារណជន

តើអ្នកបានដឹងអំពីតុលាការកាត់សេចក្ដីមេដឹកនាំខ្មែរក្រហមដែរឬទេ?




*៨២% បាទ/ចាស*
*១៨% ទេ*

តើតុលាការខ្មែរក្រហមផ្ដល់យុត្តិធម៌ដែរឬទេ?




*៧០% បាទ/ចាស, ២១% ទេ, ៩% មិនដឹង*

តើអ្នកយល់ស្របឬមិនយល់ស្របនឹងកាត់សេចក្ដីមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម?




*៦៩% បាទ/ចាស, ១៧% យល់ស្របខ្លះៗ, ៦% មិនយល់ស្របតែក៏មិនជំទាស់, ២% មិនយល់ស្របខ្លះៗ, ៣% មិនយល់ស្របទាល់តែសោះ, ៣% មិនដឹង*

*(ប្រភព: ការស្ទង់មតិរបស់អង្គការ អាយ.អ.អាយ (IRI) នៅខែកក្កដា ឆ្នាំ២០០៩)*

# ការចូលរួមរបស់សាធារណជន

អ.វ.ត.ក គឺជាតុលាការនិយាមអន្តរជាតិទី១ ដែលប្រើប្រព័ន្ធច្បាប់ស៊ិវិល និងមានការចូលរួមពីជនរងគ្រោះក្នុងនាមជាដើមបណ្ដឹងរដ្ឋប្បវេណីនិងជាដើមបណ្ដឹងធម្មតា។ ដើមបណ្ដឹងធម្មតាគឺអ្នកដែលជូនដំណឹងទៅសហព្រះរាជអាជ្ញាអំពីឧក្រិដ្ឋកម្មដែលគាត់ជឿថាត្រូវបានប្រព្រឹត្ត ហើយដើមបណ្ដឹងរដ្ឋប្បវេណីគឺជាអ្នកដែលរងគ្រោះដោយផ្ទាល់ពីឧក្រិដ្ឋកម្មដែលតុលាការកំពុងតែស៊ើបអង្កេត និងគឺជាអ្នកដែលទាមទារសំណងរដ្ឋប្បវេណីនិងសំណងសមូហភាព។

| សំណុំរឿង ០០១ | តួលេខ | |
|---|---|---|
| ពាក្យសុំដែលបានទទួល | ៩៤ | |
| ដើមបណ្ដឹងរដ្ឋប្បវេណីដែលបានចូលរួមក្នុងដំណើរការក្ដី | ៩០<br>(ដកពាក្យវិញ៣នាក់ បដិសេធ១នាក់) | |
| ស្ថានភាពនៃដើមបណ្ដឹងរដ្ឋប្បវេណីក្រោយពីការប្រកាសសាលក្រម | ទទួលយកដោយអង្គជំនុំជម្រះសាលាដំបូង | បដិសេធដោយអង្គជំនុំជម្រះសាលាដំបូង |
| | ៦៦ | ២៤ |

| សំណុំរឿង ០០២ | តួលេខ | | |
|---|---|---|---|
| ពាក្យសុំដែលបានទទួល | ៤.១០០ | | |
| ពាក្យសុំដែលនៅសេសសល់ | ៣.៩៨៥<br>(ដកពាក្យវិញ១១នាក់ ហើយ១០៤នាក់ទៀតបានផ្លាស់ប្ដូរពីពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទៅជាពាក្យបណ្ដឹងធម្មតា) | | |
| ស្ថានភាពនៃពាក្យសុំបន្ទាប់ពី ការសម្រេចចិត្តរបស់សហចៅក្រមស៊ើបអង្កេត | ទទួលយក | បដិសេធ | បាត់បង់ជីវិត |
| | **២.១២២** | **១.៨៤៥** | **១៨** |

| សំណុំរឿង ០០៣ និង ០០៤ | សរុប | សំណុំរឿង ០០៣ | សំណុំរឿង ០០៤ | សំណុំរឿងទាំងពីរ |
|---|---|---|---|---|
| **ពាក្យសុំដែលទទួលបានត្រឹម ថ្ងៃទី ១៨ ឧសភា ២០១១** | **៣១៨*** | **១៤០** | **0** | **១៧៨** |

*(ប្រភព: អង្គភាពគាំពារជនរងគ្រោះ)*

** ពាក្យបណ្ដឹងទាំងអស់នេះ លើកលែងតែពាក្យបណ្ដឹងចំនួន៤ ក៏បានដាក់នៅក្នុងសំណុំរឿង ០០១ និង/ឬ ០០២ ដែរ។ ពាក្យបណ្ដឹង៤ទៀត ក៏បានដាក់នៅក្នុងសំណុំរឿង ០០២។ ពុំមានពាក្យបណ្ដឹងថ្មីត្រូវបានដាក់មកទេ។*

# ការយល់ឃើញរបស់ជនរងគ្រោះ

តើអ្នកយល់ថា អ.វ.ត.ក ចូលរួមចំណែកក្នុងការផ្សះផ្សាជាតិដែរឬទេ?




៥៣,៩០% បាទ/ចាស

៣០,៦០% រួមចំណែកខ្លះៗ

១២,៨០% គ្មានទេ

២,៧០% មិនដឹង

តើអ្នកពេញចិត្តនឹងសាលក្រម ឌុច ដែរឬទេ?




២៥,៣០% ពេញចិត្តណាស់

៣៨,៧០% ពេញចិត្ត

១១,១០% គ្មានយោបល់

១១,១០% មិនពេញចិត្ត

១៣,៨០% មិនពេញចិត្តទាល់តែសោះ

ផ្លូវជាតិលេខ៤
សង្កាត់ចោមចៅ ខណ្ឌដង្កោ
ប្រអប់សំបុត្រលេខ ៧១
ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

**មជ្ឈមណ្ឌលព័ត៌មាន**
ផ្ទះលេខ ៦a ផ្លូវលេខ ២១
(ខាងលិចផ្សារកាប់គោ)
ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទទូទៅ +៨៥៥ (0)២៣ ២១៩ ៨១៤
ទូរសារ +៨៥៥ (0)២៣ ២១៩ ៨៤១
សម្រាប់សារព័ត៌មាន +៨៥៥ (0)១២ ៤៨៨ ០៩៤
+៨៥៥ (0)១២ ៤៨៨ ៤២១
មជ្ឈមណ្ឌលព័ត៌មាន +៨៥៥ (0)២៣ ២១៤ ២៩១
+៨៥៥ (0)២៣ ២១៤ ២៩៣
ទស្សនកិច្ចនៅតុលាការ +៨៥៥ (0)១២ ៤៨៨ ០២៩

**អ.វ.ត.ក នៅលើអ៊ិនធឺណិត**

**ECCC** www.eccc.gov.kh
**UNAKRT** www.unakrt-online.org
**Email** info@eccc.gov.kh

**Twitter** twitter.com/KRTribunal
**Flickr** www.flickr.com/krtribunal
**Facebook** www.facebook.com/krtribunal
**Youtube** www.youtube.com/krtribunal